# ការចិញ្ចឹមជ្រូក តាមបច្ចេកទេសបែបវិទ្យាសាស្រ្តធម្មជាតិ

## ១- ការចិញ្ចឹមមេជ្រូក

ត្រូវយកចិត្តទុកដាក់ដល់កត្តា ៣ជាអត្ថិភាពគឺ :

- កត្តាទី ១គឺពូជ : ពូជលូតលាស់លឿន ធន់ជំងឺ ផលិតផលកូន និងសាច់ខ្លស់មិនជាន់ឈាមគ្នា។
- កត្តាទី ២គឺចំណី : ចំណីមានគុណភាពខ្ពស់ ថាមពល និងជីវជាតិគ្រប់គ្រាន់ ស៊ីអាហារតិច ធំលឿន ។
- កត្តាទី ៣គឺបរិស្ថាន : កន្លែងធ្វើទ្រុងសមស្របល្អ ការថែទាំល្អ គ្មានជំងឺ ។

## ២- ការជ្រើសរើសពូជ

ត្រូវជ្រើសរើសពូជណាដែលកូនច្រើនសំបូរទឹកដោះ ឆ្អឹងសមរម្យល្មម និងទំងន់ដងខ្លួន ដោះគត់គូរមានសំបុកពោះជាជ្រូកមេ ជាពិសេសតំណរពូជចេញពីមេបាដែលប្រើ EX-M បានមួយជំនាន់យ៉ាងតិច ។ ជាជ្រូកដែលបង្កាត់មិនជាន់ឈាមគ្នា ។

## ៣- ការបង្កាត់

ការបង្កាត់មានពីរយ៉ាងគឺ :

- ការបង្កាត់ដោយធម្មជាតិ
- ការបង្កាត់ដោយសិប្បនិម្មិត

ត្រូវតាមដានមេជ្រូករកឈ្មោលដូចជា : ប្រដាប់ភេទប្រែប្រួល ជ្រូកឆ្លេឆ្លានៅមិនស្ងៀម ខាំ រើចរបស់ផ្សេងៗ មិនស៊ីចំណី ដេកថ្ងូរ ឡើងពាក់ជ្រូកផ្សេងៗទៀត និងមានទឹករំអិលធ្លាក់តាមប្រដាប់ភេទ ។ យកដៃសង្កត់នៅចង្កេះជ្រូក បើមេជ្រូកនៅស្ងៀមលើកត្រចៀកទាំងពីរ ក្រោយមក ១២ម៉ោង យើងអាចបង្កាត់បាន ។

ត្រូវដឹកមេជ្រូកមកនៅលើដី ឬខ្សាច់ ឬក្រាលបាវក្រចៅនៅកន្លែងដែលជ្រូកដេក បើកន្លែងនោះមាន ក្រាលស៊ីម៉ងត៍ ត្រូវយកបាវក្រចៅមកទ្រាប់លើខ្នងមេ ដើម្បីអោយបាឡើងបង្កាត់ ។
គប្បីបង្កាត់នៅពេលព្រឹក ឬពេលល្ងាច ។

ត្រូវបង្កាត់ ២ដង (ព្រឹក-ល្ងាច) បើអាចចូលបង្កាត់បា ២ផ្សេងគ្នា ក្រោយបង្កាត់យកមេជ្រូកទុកកន្លែង ផ្សេងគ្នាស្ងប់ស្ងាត់ដើម្បី តាមដាន ។

បន្ទាប់មកពី ១៩ ទៅ ២០ថ្ងៃក្រោយ បើជ្រូកមិនរកឈ្មោលទេទុកដូចជាបានការ ។

## ៩- ការថែទាំមេផើម

ការចិញ្ចឹមតាមបច្ចេកទេសវិទ្យាសាស្ត្រធម្មជាតិយើងត្រូវអនុវត្តន៍នូវករណីកិច្ចសំខាន់ ៣យ៉ាងដូច ខាងក្រោម :

ដើម្បីអោយជ្រូកមានសុខភាពល្អជារៀងរាល់ថ្ងៃយើងត្រូវផ្តល់ EX-M តាមរយៈលាយទឹកអោយផឹក ផង និងលាយជាមួយចំណីអោយស៊ីផងដែរ ។

កំរិតប្រើ :

- យកមេ EX-M ១លីត្រ លាយទឹក ១០០០០លីត្រ សំរាប់ជ្រូក តូច និងធំផឹកជារៀងរាល់ថ្ងៃ (ទឹកស្អាត ១០លីត្រ លាយមេ អ៊ី អ៊ិក្ស អិម ១សេសេ) ។ ទឹកដែលលាយផឹកនេះមិនត្រូវទុក លើស ២៤ម៉ោងទេ ។ បើផឹកនៅសល់ត្រូវយកចាក់លាងសំអាតទ្រុង ហើយបន្តលាយ សារជាថ្មីអោយជ្រូកផឹកទៀតរហូតដល់ជ្រូកបានលក់ ។
- យកមេ EX-M ១លីត្រ លាយជាមួយចំណីផ្សេងៗចំនួន ១០០ទៅ ២០០គីឡូក្រាមអោយជ្រូក ស៊ីរៀងរាល់ពេលជាប្រចាំ ។
- ឬយកមេ EX-M ៣សេសេ បូកទឹក ៣លីត្រ លាយចំណី ១០គីឡូក្រាម ដាក់អោយជ្រូកស៊ីសំ រាប់មួយពេលៗចំពោះចំណីស្ងួត ។
- យក EX-M បណ្តុញ ៣សេសេ បូកមេ EX-M ៣សេសេ បូកកាកស្ករ ៣សេសេ និងទឹកស្អាត ៣លីត្រ មកបាញ់លាងទ្រុងរៀងរាល់ ៧ថ្ងៃម្តង ។

- យកមេ EX-M ២០សេសេ បូក EX-M បណ្តេញ ២០សេសេ បូកទឹក ១០លីត្រ បាញ់អោយសព្វលើខ្លួនជ្រូក ទ្រុងជ្រូក និងបរិវេណចិញ្ចឹមដើម្បីកុំឲ្យកើតជំងឺសើស្បែក ។
- បាញ់លាងសំអាតជ្រូក និងទ្រុងរៀងរាល់ថ្ងៃ និងប្រយ័ត្នកុំអោយមេជើមលោតលេង ឬពាក់លើគ្នា ។
- មុនកើត ១សប្តាហ៍ ត្រូវដឹកជ្រូកមេទៅកន្លែងកើត ។
- លាយព្រីមិច ឬបាស់ស្មិច ក្នុងចំណីអោយជ្រូកស៊ីតាមរូបមន្តដែលបានណែនាំ ។
- ១សេសេ សំរាប់ទំងន់ជ្រូក ១០គីឡូក្រាម ចាក់សាច់ដុំ
- យកម្សៅសំរិទ្ធ ១កញ្ចប់តូច លាយជាមួយចំណីមាន់ ៥គីឡូក្រាម ក្នុងមួយសប្តាហ៍អោយមាន់ស៊ី ១ ឬ ២ដង ។
- យកម្សៅសំរិទ្ធ ១កញ្ចប់តូច លាយជាមួយទឹកស្អាត ៥លីត្រ អោយមាន់ផឹកមួយសប្តាហ៍ ២ដង ។
- កំរិតប្រើ
- ឧបត្វលីនចាក់សាច់ដុំ ២សេសេ ក្នុងជ្រូក ១ក្បាល ចាក់តែម្តងគត់ ។
- អាដេបីអឺចាក់សាច់ដុំ ៨សេសេ ក្នុង១ក្បាល ។
- ឌីណូលីទីក ចាក់សាច់ដុំ ២សេសេ ក្នុង១ក្បាល ។
- អាម៉ុកស៊ីវ៉ាល់ លាយអោយស៊ីក្នុងចំណី ៣ថ្ងៃ ជាប់គ្នា ១០០ក្រាម ក្នុងចំណី ២៥គីឡូក្រាម ។
- បើជ្រូកកើតកូនរួចមិនធ្លាក់សុក ឬមានកាកសំណល់នៅក្នុងស្បូន ត្រូវចាក់ថ្នាំ ស៊ុបព្រូស និងអាម៉ុកស៊ីវ៉ាល់ ។
- ស៊ុបព្រូស ចាក់សាចដុំ ២សេសេ ក្នុងជ្រូក ១ក្បាល តែម្តងគត់ ។

## ៥- ការថែរក្សាមេជ្រូកកើតកូន

- មុនកើតត្រូវរៀបចំកន្លែងអោយបានត្រឹមត្រូវសំរាប់បង្កើតកូនអោយជ្រូក ហើយសំភារៈដែលចាំបាច់ត្រូវត្រៀមទុកមានដូចជាកន្ត្រៃ ឡាម ជេស ក្រណាត់ស្ងួត ទ្រុងសំរាប់ដាក់កូនជ្រូក និងមេ EX-M ។ មិនគួរចាក់ទឹកលើមេជ្រូកកំពុងដង្ហក់ទេ (ពេលមេជ្រូកឈឺពោះកើតកូន) ។
- ត្រូវលាងដៃ និងសំភារៈប្រើប្រាស់ជាមួយមេ អ៊ី អ៊ិក្ស អិម ជាមុនសិន មុននឹងបង្កើតជ្រូក ។
- ពេលកូនកើតត្រូវចាប់ជើងក្រោយទាំងពីរយួរសំយុងក្បាលចុះក្រោម ដោយរលាក់ថ្មមៗ និងយកក្រណាត់ស្ងួតចាំជូតខ្លួន និងទឹកព្រៃក្នុងមាត់ ។

- ករណីកូនខ្សោយ កើតមកសន្លប់ ត្រូវផ្លុំខ្យល់ចូលត្រចៀកអោយកូនជ្រូក ឬកូនជ្រូកឈ្លក់ទឹកព្រៃត្រូវយកមាត់បឺតទឹកចេញពីច្រមុះវា ។
- យកកូនទើបកើតទុកក្នុងទ្រុង ដែលរៀបចំរួចទុកមួយអន្លើសិន ។
- ពេលកើតមកភ្លាម យើងត្រូវកាត់ផ្ចិត ហើយការកាត់កន្ទុយត្រូវលាបមេ អ៊ី អ៊ិក្ស អិម ដូចគ្នានៅចុងបញ្ចប់ទើបកាត់ធ្មេញចង្កូមលើក្រោមរបស់វា ។
- ម្យ៉ាងទៀតមិនបាច់ចង ឬកាត់ផ្ចិតក៏បាន យើងត្រូវយកផ្ចិតមកជ្រលក់មេ អ៊ី អ៊ិក្ស អិម អោយបាន ៣-៥វិនាទី រួចទុកវាមួយកន្លែង ។
- ក្រោយបង្កើតអស់ហើយ ត្រូវយកមេ អ៊ី អ៊ិក្ស អិម ជ្រលក់សំឡីជូតក្បាលដោះមេជ្រូក ទើបចាប់កូនជ្រូកដាក់អោយបៅ មិនអោយលើសពី ៤ ទៅ ៨ម៉ោង (ក្រោយកូនកើត) ។
- កន្លែងកូនជ្រូកដេកត្រូវស្ងួត និងកក់ក្តៅ ក្រោយមកនៅថ្ងៃទី ៣ យើងត្រូវចាក់ថ្នាំហ្វៃរីដិចអោយកូនជ្រូក ២សេសេ ចាក់សាច់ដុំតែម្តងគត់ ។
- ត្រូវបង្ហាត់ចំណីដល់កូនជ្រូកនៅពេលមានអាយុ ៧ថ្ងៃ ។
- គប្បីគ្រៀវជ្រូកឈ្មោលនៅពេលជ្រូកមានអាយុ ២សប្តាហ៍ បន្ទាប់ពីគ្រៀវហើយ ត្រូវលាបមេ អ៊ី អ៊ិក្ស អិម អោយបានញឹកញាប់ ។
- នៅពេលកូនជ្រូកមានអាយុ ២៥ ទៅ ២៨ថ្ងៃ ត្រូវផ្តាច់ដោះ ហើយបញ្រ្ចកមេ អ៊ី អ៊ិក្ស អិម ២សេសេ អោយកូនជ្រូកក្នុង ១ក្បាល ។

### * ចំណាំ

ក្នុងកំឡុងពេលកើតភ្លាមមេជ្រូក បាក់កំលាំងខ្សោយមិនសូវសំបូរទឹកដោះត្រូវចាក់ថ្នាំ អុកស៊ីតុកស៊ីនតាមសរសៃវ៉ែន (ស្លឹកត្រចៀក) កន្លះសេសេ ព្រឹក-ល្ងាច និងចាក់ថ្នាំខារ៉ាស៊ីល (Carasil) ដើម្បីបង្កើនកំលាំងធ្វើអោយសំបូរទឹកដោះ និងធ្វើអោយជ្រូកឃ្លានចំណី ។

កំរិតប្រើ :

- ខារ៉ាស៊ីល ១ ទៅ ២សេសេ ក្នុង ១ក្បាល សំរាប់កូនជ្រូក ។
- ១០សេសេ ក្នុង ១ក្បាល សំរាប់មេជ្រូក (ចាក់សាច់ដុំ) ។
- ករណីកូនកំពុងបៅមានជំងឺរាគត្រូវយកមេ អ៊ី អ៊ិក្ស អិម ២-៣សេសេ បញ្រ្ចកកូនជ្រូកនោះ (ព្រឹក-ល្ងាច) ២ ទៅ ៣ថ្ងៃជាប់គ្នា ។

## ៦- ការចិញ្ចឹមជ្រូកសាច់

ការរៀបចំទ្រុងត្រូវយក អ៊ី អុិក្ស អិម បណ្ដេញ ២០សេសេ បូកមេ EX-M ២០សេសេ បូកទឹក ១០លីត្រ បាញ់លាងទ្រុង ៣ថ្ងៃ ជាប់គ្នារួចទុកចោលរយៈពេល ៥ថ្ងៃ ។ ដុសលាង សំអាតឧបករណ៍ ធុងទឹក ស្នូកចំណី និងវិធីប្រើប្រាស់ដូចខាងលើ ហើយត្រូវមានបំរុងមេ EX-M និងកាកស្ករសំរាប់អោយមេ ជ្រូកផឹក ស៊ី ។

ត្រូវបញ្ចូលជ្រូកក្នុងទ្រុង បន្ទាប់ពីដាក់ជ្រូកចូលទ្រុងហើយត្រូវពិនិត្យមើល :

- បើមានជ្រូកណាមិនស្រួលត្រូវដេកទុកកន្លែងផ្សេងដើម្បីព្យាបាល ។
- បន្តលាយទឹក និងមេ EX-M តាមក្បូនខ្នាតអោយជ្រូកផឹកជានិច្ច ។
- អនុវត្តន៍បែបនេះ សំរាប់ជ្រូកដែលចេញពីទ្រុង ចិញ្ចឹមតាមបច្ចេកទេសវិទ្យាសាស្រ្តធម្មជាតិ ។

ការថែរក្សា បោស បាញ់ លាងសំអាតទ្រុង :

- លាយ EX-M សន្សំសំចៃនៅក្នុងអាងទឹកជ្រូកដេករៀងរាល់ ២៤ម៉ោងម្តង។
- លាយមេ EX-M អោយជ្រូកផឹកជារៀងរាល់ ២៤ម៉ោងម្តង។
- លាយមេ EX-M បូកកាកស្ករ បូកទឹក បូកជាមួយចំណី អោយជ្រូកស៊ីរៀងរាល់ពេល ធ្វើ ១ ពេលសំរាប់ ១ពេល(ហាមធ្វើលាយផ្អាប់ទុក) ។
- យក EX-M បណ្ដេញ បូកមេ EX-M បូកទឹក បាញ់លាងទ្រុង និងបាញ់លើជ្រូករៀងរាល់ពី ៥ ទៅ ៧ថ្ងៃម្តង
- ត្រូវចាក់វីតាមីន ស្រេ្តសវីតា ក្នុង១ខែម្តង ។

### * ចំណាំ

ពិសេសអនុវត្តន៍តាមការណែនាំខាងលើ ជ្រូកមានសុខភាពរឹងមាំល្អ មិនឈឺ ឆាប់ធំធាត់ សាច់ច្រើន គ្មានជាតិគីមី សាច់មានជីវជាតិឆ្ងាញ់ ចំណេញច្រើនក្នុងការចិញ្ចឹម ។

ថ្នាំសំរាប់ព្យាបាលមេជ្រូក

ព្យាបាលរលាកសួត រាគ ផ្សុះស្បូន លាសដោះ និងផ្តាសសាយកូនជ្រូក ថ្នាំស៊ុលហ្វាពព (SULFA33)

កំរិតប្រើ :

- ចាក់សាច់ដុំជ្រូកធំ ១-៥មីលីលីត្រ ក្នុងទំងន់ ១០គីឡូក្រាម
- ជ្រូកផ្តាច់ដោះរហូតដល់ ៥០គីឡូក្រាម ៥-៨មីលីលីត្រ
- កូនជ្រូក ១-២មីលីលីត្រ ក្នុង១ក្បាល

កំរិតប្រើ : លាយក្នុងចំណីអោយស៊ី ១គីឡូក្រាម ក្នុង ១០០គីឡូក្រាម ចំណីអោយស៊ីរយៈពេល ៧ថ្ងៃ

## វិធីផ្សំអាហារជ្រូក

### វិធីផ្សំទី ១

| វត្ថុផ្សំ | ផ្តាច់ដោះ-២០ គ.ក | ២០-៥០ គ.ក | ៥០ គ.ក-លក់ | មេផើម និងមេចិញ្ចឹមកូន |
|---|---|---|---|---|
| ចុងអង្ករ | ៥០ គ.ក | ៦០ គ.ក | ៥០ គ.ក | ៨០ គ.ក |
| ពោត | | ៥០ គ.ក | ១៦០ គ.ក | |
| កន្ទក់ | ១៨ គ.ក | ៥៨ គ.ក | ៧២ គ.ក | ៦០ គ.ក |
| សណ្តែកសៀងលីង | ១៥ គ.ក | ៥០ គ.ក | ៧២ គ.ក | ២០ គ.ក |
| សណ្តែកដីលីង | ៥ គ.ក | | | ២៥ គ.ក |
| ត្រីម៉ត់ | ៣ គ.ក | ៦ គ.ក | ១៥ គ.ក | ៣.៥ គ.ក |
| ម្សៅខ្យង | ១ គ.ក | ២ គ.ក | | ១ គ.ក |
| អំបិល | ០.៣ គ.ក | ០.៦ គ.ក | ១.៦ គ.ក | ០.៥ គ.ក |
| ព្រីមិច ឬ បាស្មិច | ០.៥ គ.ក | ១ គ.ក | ២ គ.ក | ១ គ.ក |
| ខ្លាញ់ | ១ គ.ក | | | ០.៣៥ គ.ក |
| មេអាហារសត្វ | ២ គ.ក | ៤ គ.ក | ៧ គ.ក | ៤ គ.ក |
| សរុប | ៩៥.៨ គ.ក | ២០១.៦ គ.ក | ៣៦៨.៦ គ.ក | ១៧០.៣៥ គ.ក |
| ប្រូទីន | ២០% | ១៨% | ១៦% | ១៨% |

* ព្យាបាលរាគប្រផេះ និង រាគឈាម ដំបៅក្រចក ជំងឺសារទឹក ដោយទីឡូស៊ីន (TYLOSIN) ២០០ (២០%)

កំរិតប្រើ :

- ចាក់សាច់ដុំជ្រូក ចាក់ ១សេសេ សំរាប់ ២០គីឡូក្រាម ។
- គោចាក់ ១សេសេ សំរាប់ ២៥គីឡូក្រាម ។
- ចាក់ ១ថ្ងៃម្តង ព្យាបាលរយៈពេល ៣-៥ថ្ងៃ ។

* ព្យាបាលមេជ្រូកដែលរកឈ្មោលមិនទៀងទាត់ ឬដាក់បាមិនជាប់ ប្រើនៅពេលបង្កាត់ និងព្យាបាលហូរខ្ទុះក្រោយពេលដាក់បា ។ ព្យាបាលកូនជ្រូកប្រកាច់ដោយស្ត្រិបតូកុក ចំពោះកូនជ្រូកផ្តាច់ដោះ ។ កំរិតប្រើ : លាយក្នុងចំណីអោយស៊ី ១គីឡូក្រាម ក្នុង ១០០គីឡូក្រាម ចំណីអោយស៊ីរយៈពេល ៧ថ្ងៃ

### វិធីផ្សំទី ២

| វត្ថុផ្សំ | ១៥-៣០ គ.ក | ៣០-៦០ គ.ក | ៦០ គ.ក-លក់ | មេផើម | មេចិញ្ចឹមកូន |
|---|---|---|---|---|---|
| ពោត | ៥០ គ.ក | ៤៨ គ.ក | ៣៨ គ.ក | ៤៥ គ.ក | ៤០ គ.ក |
| ដំឡូងមី | ៦ គ.ក | ១០ គ.ក | ១៤.៥ គ.ក | ០ គ.ក | ៥ គ.ក |
| កន្ទក់ | ១០ គ.ក | ៧ គ.ក | ១០ គ.ក | ៥ គ.ក | ១០ គ.ក |
| កន្ទក់សាឡី | ៤.៣ គ.ក | ១០ គ.ក | ១៣.៥ គ.ក | ៣៥ គ.ក | ២៣ គ.ក |
| សណ្តែកសៀងលីង | ១៩ គ.ក | ១៨ គ.ក | ១៨ គ.ក | ១០ គ.ក | ១៥ គ.ក |
| ម្សៅត្រី | ៧.៣ គ.ក | ៦.៧ គ.ក | ២.៣ គ.ក | ១.២ គ.ក | ៣ គ.ក |
| ដេសេប៉េ | ១ គ.ក | ០.១៥ គ.ក | ០.២ គ.ក | ០.២៥ គ.ក | ១.១៥ គ.ក |
| សំបកងាវ | ១ គ.ក | ១.៦៥ គ.ក | ២ គ.ក | ២ គ.ក | ១.៥ គ.ក |
| អំបិល | ០.៤ គ.ក | ០.៥ គ.ក | ០.៥ គ.ក | ០.៥៥ គ.ក | ០.៣៥ គ.ក |
| បាស៊ិច | ១ គ.ក | ១ គ.ក | ១ គ.ក | ១ គ.ក | ១ គ.ក |
| មេអាហារសត្វ | ២ គ.ក | ២ គ.ក | ២ គ.ក | ២ គ.ក | ២ គ.ក |

## វិធីផ្សំទី ៣

| វត្ថុផ្សំ | ១៥-៣០ គ.ក | ៣០-៦០ គ.ក | ៦០ គ.ក-លក់ | មេធើម | មេចិញ្ចឹមកូន |
|---|---|---|---|---|---|
| ស្រូវកិន | ៦០ គ.ក | ៦៥ គ.ក | ៦០ គ.ក | ៦០ គ.ក | ៥៥ គ.ក |
| កន្ទក់ | ១១ គ.ក | ១៥ គ.ក | ២០ គ.ក | ៣០ គ.ក | ២៥ គ.ក |
| សណ្តែកសៀងលីង | ១៥ គ.ក | ១៣ គ.ក | ១៣ គ.ក | ៥ គ.ក | ១០ គ.ក |
| ត្រីម៉ត់ | ៨ គ.ក | ៤ គ.ក | ៣ គ.ក | ១.៥ គ.ក | ៣ គ.ក |
| ដេសេប៉េ | ១ គ.ក | ០.១៥ គ.ក | ០.២ គ.ក | ០.២៥ គ.ក | ១.១៥ គ.ក |
| សំបកងាវ | ១ គ.ក | ១.៧ គ.ក | ២ គ.ក | ២ គ.ក | ១.៥ គ.ក |
| អំបិល | ០.៤ គ.ក | ០.៥ គ.ក | ០.៥ គ.ក | ០.៥៥ គ.ក | ០.៣៥ គ.ក |
| បាស្មិច | ១ គ.ក | ១ គ.ក | ១ គ.ក | ១ គ.ក | ១ គ.ក |
| មេអាហារសត្វ | ២ គ.ក | ២ គ.ក | ២ គ.ក | ២ គ.ក | ២ គ.ក |

ថ្នាំសំរាប់ព្យាបាលជ្រូកសាច់ ឬកូនជ្រូកគ្រុនក្តៅ បញ្ចុះកំដៅ និងបំបាត់ការស្ពឹកស្រពន់

កំរិតប្រើ :

- កូនជ្រូក : ចាក់ ១-២សេសេ ក្នុង១ក្បាល សំរាប់ ១ថ្ងៃចាក់ ២ដង ។
- ជ្រូកសាច់ : ចាក់ ១-២សេសេ ក្នុង១ក្បាល សំរាប់ ១ថ្ងៃចាក់ ២ដង ។
- មេជ្រូក : ចាក់ ១-២សេសេ ក្នុង១ក្បាល សំរាប់ ១ថ្ងៃចាក់ ២ដង ។
  (ហាមប្រើពេលមេជ្រូកជិតកើត និងក្រោយពេលកើតកូន)

ការពារជំងឺឆ្លងផ្សេងៗ (ពេលផ្លាស់ប្តូរកន្លែង) ការពារជំងឺក្អក និងរាគដែលមានលាមកពណ៌ប្រផេះ និងលាមកមានឈាម ចំពោះជ្រូកសាច់ត្រូវប្រើថ្នាំ Tylocycline ។
កំរិតប្រើ : Tylocycline ៥គីឡូក្រាម ក្នុងចំណី ១តោន អោយស៊ីរយៈពេល ៥ថ្ងៃ ។

(ដកស្រង់ចេញពី ព្រុំ សុភាព ប្លុក)